**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ បារាំង និង ខ្មែរ

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 02-Dec-2013, 16:00
CMS/CFO: Sann Rada

### <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ និងខ្លះៗសម្ងាត់សំខាន់**

ចំណាត់ថ្នាក់ឯកសារដោយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## ព័ត៌មានបន្ថែមលើសំណើសុំចុងក្រោយស្ដីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**<u>ចម្លងជូន៖</u>**

---

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យ៉ុង ផានិត

សំ សុគង់

វ៉េន ពៅ

ទី ស្រ៊ីនណា

គង់ ផល្លៈ

Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Jeanne SULZER
Philippine SUTZ
Beini YE

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Pascal AUBOIN

## I. សេចក្តីផ្តើម

១. តាមរយៈសារណានេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានបន្ថែមស្តីពីហិរញ្ញប្បទានលើគម្រោងសំណងមួយ ដែលបានលើកឡើងនៅក្នុងសំណើសុំសំណងចុងក្រោយ ក្នុងសំណុំរឿង ០០២/០១។

២. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើសុំចុងក្រោយ អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង[1]។ នៅក្នុងសំណើសុំនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ជូនអង្គជំនុំជម្រះថា *"បន្ទាប់ពីការដាក់សំណើសុំចុងក្រោយនេះ រហូតដល់ការចេញសេចក្តីសម្រេចចុងក្រោយ ខ្លួននឹងប្រគល់ជូនអង្គជំនុំជម្រះ និងភាគីទាំងអស់ នូវរាល់ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងស្ថានភាពថវិការបស់គម្រោងនីមួយៗ ហើយនឹងព័ត៌មានដែលមកបំពេញស្ថានភាពនេះ"*[2]។

៣. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅតែបន្តខិតខំប្រឹងប្រែងស្វែងរកហិរញ្ញប្បទានបន្ថែម ដោយមានការឧបត្ថម្ភគាំទ្រពីផ្នែកគាំពារជនរងគ្រោះ និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ។

៤. នៅក្នុងសំណើសុំចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យទទួលស្គាល់ជាសំណងនូវជំពូកជាក់លាក់ ដែលនឹងត្រូវបញ្ចូលទៅក្នុងសៀវភៅបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រខ្មែរក្រហម។

៥. ដូចបានបញ្ជាក់ជូនក្នុងសំណើសុំចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជំពូកនេះចែកជា ៤ មេរៀន មាន ១៦ ទំព័រ ហើយនិយាយអំពីគោលនយោបាយជម្លៀសប្រជាជន

---

[1] សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ E218/7/6។

[2] ដូចខាងលើ កថាខណ្ឌ ២៤១ ERN KH 00952737-00952738។

ដោយបង្ខំជាទូទៅ[3] និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ ជំពូកនេះនឹងត្រូវដាក់បន្ថែមទៅក្នុងសៀវភៅសិក្សាអំពីខ្មែរក្រហម ដែលបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានដាក់ឲ្យគ្រូបង្រៀនប្រើប្រាស់រួចហើយ។ ខ្លឹមសារនឹងត្រូវគាក់តែង ក្រោយពេលប្រកាសសេចក្តីសម្រេចរបស់តុលាការ ដោយគោរពយ៉ាងម៉ឺងម៉ាត់តាមបញ្ញត្តិនៃសេចក្តីសម្រេចនេះ។

៦. មជ្ឈមណ្ឌលឯកសារកម្ពុជា បានសន្យាថានឹងសម្រេចគម្រោងនេះ[4]។ ដូចបានចង្អុលបង្ហាញនៅក្នុងសំណើសុំចុងក្រោយ គម្រោងនេះនឹងត្រូវអនុវត្ត ក្រោយពីប្រកាសសេចក្តីសម្រេច ក្នុងសំណុំរឿង ០០២/០១ ពីព្រោះគម្រោងនេះសំដៅបំពេញបន្ថែមលើការបង្រៀនប្រវត្តិសាស្ត្រ ដោយផ្អែកលើសាលក្រមនៃសំណុំរឿង ០០២/០១។

៧. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) បានប្រកាសផ្តល់វិភាគទានដល់គម្រោងនេះ ក្នុងទឹកប្រាក់ចំនួន ៥៧.១៦០ ដុល្លារ[5]។

៨. ដូច្នេះ មកទល់នឹងសព្វថ្ងៃនេះ គម្រោងត្រូវបានផ្តល់ហិរញ្ញប្បទានមួយផ្នែក ដោយវិទ្យាស្ថានស្លឹករឹតដែលមានប្រភពចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល[6] និងមួយផ្នែកទៀត ដោយ GIZ ក្នុងទឹកប្រាក់រៀងគ្នាចំនួន ៤០.០០០ ដុល្លារ[7] និង ៥៧.១៦០ ដុល្លារ ស្មើនឹងហិរញ្ញប្បទានសរុប ៩៧.១៦០ ដុល្លារ។

---

[3] ដូចខាងលើ កថាខណ្ឌ ១៩០ ERN KH 00952727-00952728 *"មេរៀនទី ១ និយាយអំពីគោលនយោបាយ គោលបំណង ព្រមទាំងដំណាក់កាលផ្សេងៗនៃការជម្លៀស។ មេរៀនទី ២ លើកឡើងពីការរាយរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីអ្វីដែលគាត់បានជួបប្រទះក្នុងអំឡុងពេលជម្លៀស។ មេរៀនទី ៣ លើកឡើងអំពីផលវិបាកនៃការជម្លៀសដោយបង្ខំទៅលើជនរងគ្រោះ។ ចំណែកមេរៀនទី ៤ លើកឡើងជាពិសេសអំពីទួលពោធិ៍ជ្រៃ ដោយផ្តោតជាពិសេសលើស្ថានភាព និងការសម្លាប់រង្គាលនៅទីនោះ ព្រមទាំងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី"*។

[4] សូមមើលឯកសារ E218/7/6.1.6 ERN 00950969-00950970។

[5] សូមមើលឧបសម្ព័ន្ធសម្ងាត់ទី ១។

[6] សូមមើលឯកសារ E218/7/6.1.6 ERN 00950977-00950978។

[7] សូមមើលឯកសារ E218/7/6.1.6 ERN 00950979។

**អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមអង្គជំនុំជម្រះសាលាដំបូងមេត្តា**

- ពិចារណាទៅលើសេចក្តីបញ្ជាក់ថ្មី ដែលដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ជូន តាមរយៈសារណាស្តីពីស្ថានភាពហិរញ្ញប្បទាននៃគម្រោងខាងលើនេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួននៅពេលខាងមុខ សំដៅទទួលស្គាល់គម្រោងដែលបានបង្ហាញ ជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២/០១។

រក្សាសិទ្ធិកែប្រែ

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | រាជធានីភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | រាជធានីភ្នំពេញ | |